ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.ធ៦២.០២០.០៥៥ ប្រកាសព័ត៌មាន

ថ្ងៃសុក្រ ១៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីការដាក់ទណ្ឌកម្មខាងវិន័យផ្នែកហិរញ្ញវត្ថុចំពោះបុគ្គលរាយការណ៍ដែលមិនអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

នៅថ្ងៃព្រហស្បតិ៍ ១២រោច ដល់ថ្ងៃសុក្រ ១៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២០-២១ ខែកុម្ភៈ ឆ្នាំ២០២០ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានរៀបចំសិក្ខាសាលាស្តីពីការដាក់ទណ្ឌកម្មខាងវិន័យផ្នែកហិរញ្ញវត្ថុ ចំពោះបុគ្គលរាយការណ៍ដែលមិនអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ចំនួន៤សិក្ខាសាលាសម្រាប់ (១)-គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន១៣៦នាក់ (២)-គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានសិក្ខាកាមចូលរួមចំនួន១៥២នាក់ (៣)-ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ គ្រឹះស្ថានផ្តល់សេវាទូទាត់ អ្នកដំណើរការតតិយភាគី អាជីវកម្មប្តូរប្រាក់ និងគ្រឹះស្ថានផ្សេងទៀតដែលស្ថិតក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ដែលមានសិក្ខាកាមចូលរួមចំនួន១៣០នាក់ និង(៤)-ក្រុមហ៊ុនកាស៊ីណូ ក្រុមហ៊ុនអចលនទ្រព្យ និងសមាគមអ្នកអភិវឌ្ឍន៍លំនៅដ្ឋានកម្ពុជា ដែលមានសិក្ខាកាមចូលរួមចំនួន៣៣០នាក់។ សិក្ខាសាលាទាំង៤នេះមានគោលបំណងផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីកាតព្វកិច្ចនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងកាតព្វកិច្ចផ្សេងៗ ព្រមទាំងដាក់ពិន័យចំពោះគ្រឹះស្ថានទាំងឡាយណាដែលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាពិនិត្យឃើញថា ពុំបានអនុវត្តទៅតាមកាតព្វកិច្ចទាំងនេះ។ តាមរយៈសិក្ខាសាលានេះ សិក្ខាកាមទាំងអស់បានទទួលចំណេះដឹងបន្ថែមអំពីការតម្រូវទាំងឡាយ ដែលមានចែងនៅក្នុងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងផលវិបាកព្រមទាំងបញ្ហាប្រឈមនានា នៅពេលមានការខកខានពុំអនុវត្តតាមតម្រូវការទាំងនេះ។

សូមបញ្ជាក់ថាកាលពីថ្ងៃសុក្រ ១៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បានដាក់ឲ្យប្រើប្រាស់ប្រកាសស្តីពីការដាក់ទណ្ឌកម្មខាងវិន័យផ្នែកហិរញ្ញវត្ថុ ចំពោះបុគ្គលរាយការណ៍ ដែលមិនអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ប្រកាសនេះនឹងអនុវត្តចំពោះគ្រប់បុគ្គលរាយការណ៍ដែលមានចែងក្នុងមាត្រា៤នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដោយគ្របដណ្តប់វិធានការទណ្ឌកម្មជាពីរផ្នែកធំៗគឺ (១)-ការប្រតិបត្តិតាមច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង(២)-កាលបរិច្ឆេទផ្តល់របាយការណ៍និងព័ត៌មានផ្សេងៗ។